**សម្តេចពិជ័យសេនា ទៀ បាញ់**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខផ្ញើជូន

## លោកជំទាវ លាង មួចឆេង ហ៊ុន ឈេង ព្រមទាំងក្រុមគ្រួសារនៃសព

**លោកជំទាវ ជាទីរាប់អាន!**

ខ្ញុំនិងភរិយា ព្រមទាំងថ្នាក់ដឹកនាំ នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ មានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ចំពោះដំណឹងដ៏ក្រៀមក្រំនៃមរណភាពរបស់ **ឯកឧត្តម ហ៊ុន ឈេង** សមាជិកអចិន្ត្រៃយ៍រដ្ឋសភា អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម និងជាប្រធានគណៈកម្មការទី៤នៃរដ្ឋសភា ដែលឯកឧត្តមបានទទួលមរណភាពនៅថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៨:២៥នាទី ក្នុងជន្មាយុ៧២ឆ្នាំ ដោយរោគាពាធ។

**ឯកឧត្តម ហ៊ុន ឈេង** គឺជាកុលបុត្រខ្មែរដ៏ឆ្នើម និងជាវីរជនប្រកបដោយស្មារតី និងឆន្ទៈស្នេហាជាតិដ៏មោះមុតមួយរូប ដែលធ្លាប់បានបូជាកម្លាំងកាយ និងប្រាជ្ញាស្មារតី ពុះពារមិនខ្លាចនឿយហត់ចូលរួមក្នុងបុព្វហេតុជាតិ មាតុភូមិ ប្រជាជន និងបានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់តម្លៃនៃនីតិរដ្ឋប្រកបដោយឧត្តមគតិខ្ពង់ខ្ពស់ ជាអនេកប្បការ។ មរណភាពរបស់**ឯកឧត្តម ហ៊ុន ឈេង** មិនត្រឹមតែជាការបាត់បង់នូវស្វាមី ឪពុក និងជីតា ជាទីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅប្រកបដោយគុណធម៌ ព្រហ្មវិហារធម៌មិនចេះរីងស្ងួតប៉ុណ្ណោះទេ ពិសេសជាការបាត់បង់ដ៏ធំធេងនូវឥស្សរជននយោបាយខ្មែរដ៏ឆ្នើមមួយរូប ដែលពោរពេញដោយឆន្ទៈមនសិការ ក្នុងការបម្រើបុព្វហេតុ **ជាតិ សាសនា ព្រះមហាក្សត្រ** គ្រប់កាលៈទេសៈ។

ខណៈនេះ ខ្ញុំនិងភរិយា នាយទាហាន នាយទាហានរង និងពលទាហាន សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធសព **ឯកឧត្តម ហ៊ុន ឈេង** សូមធាប់បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកជំទាវ ព្រមទាំងក្រុមគ្រួសារនៃសព ទទួលនូវសេចក្តីរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

ថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**